Tuberculosis - Fact Sheet
ជម្ងឺរបេង - ចុលួលិខិតការពិត

តើជម្ងឺរបេងជាអ្វី?

ជម្ងឺរបេង (TB) គឺជាជម្ងឺឆ្លងមួយដែលបណ្តាលមកពីបាក់តេរីរបេង (មេរោគ) ដែលត្រូវបានស្រូបចូលទៅក្នុងសួតរបស់បុគ្គលណាម្នាក់ ។ បាក់តេរីទាំងនេះអាចឆ្លងទៅក្នុងលំហរអាកាស នៅពេលមានជនណាម្នាក់ដែលមានមេរោគរបេងសកម្មនៅក្នុងសួតនោះក្អក កណ្តាស់ ឬនិយាយ ។

របៀបទូទៅនៃការចម្លងមេរោគរបេង គឺដោយសារការចំណាយពេលក្នុងផ្ទះច្រើនជាមួយនឹងអ្នកដែលមានជម្ងឺរបេង ។ បាក់តេរីរបេងមិនអាចឆ្លងទៅអ្នកឯទៀតដោយសារការប្រើចាន ពែងទឹក ឬរបស់ផ្សេងទៀតឡើយ ។

តើអ្នកណាអាចមានជម្ងឺរបេងនេះ?

ចំនួននៃអ្នកដែលមានជម្ងឺរបេងនៅក្នុងរដ្ឋវិចតូរីយ៉ាគឺមានតិចណាស់ ។ ទោះបីជាយ៉ាងណាក្តី គឺមានក្រុមខ្លះនៅក្នុងសហគមន៍ស្ថិតនៅក្នុងសភាពគ្រោះថ្នាក់នៃជម្ងឺរបេងកាន់តែច្រើនឡើងៗ ។ ជនទាំងនេះរាប់បញ្ចូលទាំង:

- ជនអន្តោប្រវេសន៍ និងជនភៀសខ្លួន ជាពិសេសអស់អ្នកដែលមកពីប្រទេសបំរុងនឹងជឿនលឿន ។
- ជនជាតិអាប៊ូរីជីនី និងអ្នករស់នៅតាមកោះ Torres Strait ។
- អ្នកវិជ្ជាជីវៈខាងផ្នែកសុខភាព ។
- អ្នកប្រមឹក ។
- មនុស្សចាស់ ។
- អ្នករស់នៅតាមគ្រឹះស្ថាន រាប់បញ្ចូលទាំងអ្នកទោស ។
- អ្នករស់នៅតាមទីកន្លែងក្រីក្រ មនុស្សដែលរស់នៅច្រើនមូលផ្តុំគ្នា (ជម្ងឺរបេងច្រើនកើតមាននៅតាមសហគមន៍ដែលមានមនុស្សក្រីក្ររស់នៅច្រើន) ។
- អស់អ្នកដែលមានមេរោគហ៊ីវ (HIV) និងជម្ងឺអេដស៍ (AIDS)។
- អ្នកដែលប្រើថ្នាំដើម្បីធ្វើឲ្យសាំនឹងរោគ ជាពិសេសអស់អ្នកដែលប្រើថ្នាំស្តេរ៉ូយ សំរាប់រយៈពេលវែង ។
- អ្នកមានជម្ងឺទឹកនោមផ្អែម ។

របៀបដែលជម្ងឺរបេងប៉ះពាល់ទៅដល់ដងខ្លួន

មេរោគរបេង

បាក់តេរីរបេងបានត្រូវស្រូបចូលទៅក្នុងសួត ជាកន្លែងមួយដែលវាចាប់ផ្តើមកកើតជាច្រើនឡើង។ ។ មានខ្លះរុករានចូលទៅក្នុងផ្នែកឯទៀតនៃដងខ្លួនដូចជាតម្រងទឹកនោម ឆ្អឹង និងខួរក្បាល ។ ឥឡូវជននោះកើតមានរោគរបេងហើយ ។ ដងខ្លួនក៏ចាប់ផ្តើមប្រឆាំងតប ក៏ប៉ុន្តែតាមធម្មតាវាមិនអាចសម្លាប់អស់ទាំងបាក់តេរីទេ ។ គ្រឿងការពាររបស់ដងខ្លួនក៏បង្កើតកន្សោម ឬជញ្ជាំងព័ទ្ធជុំវិញបាក់តេរីនោះដែលវានៅក្នុងដងខ្លួនដោយអសកម្ម ហើយជននោះមានអារម្មណ៍ល្អដូចធម្មតា ។

ជនដែលមានមេរោគរបេង មានបាក់តេរីរបេងនៅក្នុងដងខ្លួនរបស់គេ ក៏ប៉ុន្តែឥតមានរោគសញ្ញាប្រាប់ថាមានជម្ងឺទេ ហើយក៏មិនអាចចម្លងមេរោគរបេងនេះទៅដល់អ្នកឯទៀតឡើយ ។

ការព្យាបាលដោយប្រើថ្នាំពេទ្យនៅត្រង់ចំណុចនេះ នឹងអាចជួយបង្ការបាក់តេរីរបេងកុំឲ្យកើតមានជម្ងឺរបេង ។

ជម្ងឺរបេង

ប្រសិនបើបាក់តេរីនោះទៅជាសកម្ម ហើយចាប់ផ្តើមកកើតជាច្រើនឡើង។ ជននោះក៏កើតមានជម្ងឺរបេង ឬរបេងសកម្ម ។ នេះអាចកើតមានឡើងក្នុងរយៈពេល១ឆ្នាំ ឬច្រើនឆ្នាំក្រោយមកតាមធម្មតាគឺនៅ ពេលណាខ្លួនប្រាណចាប់ផ្តើមអន់ខ្សោយមិនអាចតយុទ្ធនឹងជម្ងឺឆ្លង និងជម្ងឺឯទៀតដូចជាមេរោគហ៊ីវ/ជម្ងឺអេដស៍ ជម្ងឺទឹកនោមផ្អែម ជម្ងឺតម្រងនោម ជម្ងឺហើមទងសួត ឬជម្ងឺមហារីក ។

ជនដែលមានជម្ងឺរបេងគឺមានបាក់តេរីរបេង ហើយមានរោគសញ្ញាខ្លះដែលអាចរាប់បញ្ចូលទាំងក្អក អស់កម្លាំង បែកញើសនៅពេលយប់ ចុះទម្ងន់ ហើយក្អកចេញឈាម ។ ជនដែលមានជម្ងឺនេះអាចចម្លងមេរោគទៅដល់អ្នកឯទៀត ។

ការធ្វើតេស្តពិនិត្យមើលគឺងាយស្រួល

ការធ្វើតេស្តពិនិត្យមើលស្បែក (Mantoux Test) អាចបង្ហាញប្រាប់ ប្រសិនបើលោកអ្នកមានបាក់តេរីរបេងនៅក្នុងខ្លួនរបស់លោកអ្នក ។ គេនឹងចាក់សារធាតុដែលមិនធ្វើទុក្ខចូលទៅក្រោមស្បែកដៃរបស់លោកអ្នក ហើយអ្នកវិជ្ជាជីវៈខាងថែទាំសុខភាពមួយរូប ត្រូវតែឆែកមើលស្បែកនោះក្នុងរយៈពេល២ ឬ៣ថ្ងៃក្រោយមកដើម្បីពិនិត្យរកមើលការហើមណាមួយ ។ នេះគឺជាការសំខាន់ណាស់ដែលលោកអ្នកត្រូវតែឲ្យគេឆែកមើលស្បែករបស់លោកអ្នក នៅចំថ្ងៃដែលគេប្រាប់លោកអ្នកឲ្យត្រឡប់ទៅវិញ ។ លោកអ្នកនឹងបានទទួលលទ្ធផលធ្វើរបស់លោកអ្នក ហើយនឹងបានទទួលដំណឹង ប្រសិនបើគេតម្រូវឲ្យលោកអ្នកធ្វើតេស្តបន្ថែមទៀត។

តើនរណាគួរតែធ្វើតេស្ត?

អ្នកដែល:

- មានមេរោគហ៊ីវ/ជម្ងឺអេដស៍
- រស់នៅ និងធ្វើការជិតស្និទ្ធជាមួយជនដែលអាចមានជម្ងឺរបេង ។
- មានរោគសញ្ញានៃជម្ងឺរបេង ។

តើលទ្ធផលនៃការធ្វើតេស្តមានន័យដូចម្តេច

លទ្ធផលអវិជ្ជមាននៃការធ្វើតេស្ត

លទ្ធផលអវិជ្ជមាននៃការធ្វើតេស្ត មានន័យថាលោកអ្នកប្រហែលជាមិនមានបាក់តេរីរបេងនៅក្នុងខ្លួនរបស់លោកអ្នកទេ ក៏ប៉ុន្តែលោកអ្នកប្រហែលជាត្រូវការធ្វើតេស្តស្បែកមួយទៀត ដើម្បីឲ្យបានដឹងច្បាស់ជ្រាកដ ។ ប្រសិនបើលោកអ្នកមានមេរោគហ៊ីវ ឬជម្ងឺអេដស៍ នោះវេជ្ជបណ្ឌិតរបស់លោកអ្នកប្រហែលជាចង់ឲ្យលោកអ្នកធ្វើតេស្តមួយចំនួនទៀត ដ្បិតអីតាមធម្មតាការធ្វើតេស្តស្បែកមិនអាចបង្ហាញការរកឃើញជម្ងឺរបេងនៅក្នុងចំណោមជនដែលមានមេរោគហ៊ីវ ឬជម្ងឺអេដស៍នោះឡើយ ។

លទ្ធផលវិជ្ជមាននៃការធ្វើតេស្ត

លទ្ធផលវិជ្ជមាននៃការធ្វើតេស្ត អាចមានន័យថាលោកអ្នកមានមេរោគរបេង ។ តេស្តនេះនឹងមិនបង្ហាញច្បាស់ថាលោកអ្នកមានជម្ងឺរបេង ឬថាលោកអ្នកអាចចម្លងទៅដល់អ្នកឯទៀតឡើយ ។ ការធ្វើតេស្តជាច្រើនទៀតនឹងត្រូវឲ្យមានជាចាំបាច់ ដូចជាការថតមើលដើមទ្រូងដោយប្រើកម្សៃស្ម៊ីអ៊ិក្ស និងប្រហែលជាមានការធ្វើតេស្តមួយចំនួនទៀត ដើម្បីឲ្យបានដឹងថាលោកអ្នកមានជម្ងឺរបេងឬទេ និងដើម្បីពិចារណាលើថ្នាំព្យាបាលដែលលោកអ្នកត្រូវការ ។

ការព្យាបាលជម្ងឺរបេង

ប្រភេទនៃការព្យាបាលជម្ងឺរបេងដែលត្រូវការនោះ គឺអាស្រ័យថាតើជននោះមានមេរោគរបេង ឬជម្ងឺរបេង ។

ជម្ងឺរបេង ហើយក្នុងករណីយនៃមេរោគរបេងខ្លះទៀត នឹងត្រូវព្យាបាលជាមួយនឹងថ្នាំពេទ្យ ។ ថ្នាំពេទ្យសម័យគឺមានប្រសិទ្ធិភាពក្នុងការព្យាបាលជម្ងឺរបេង ។

ការព្យាបាលសំរាប់មនុស្សភាគច្រើន គឺអាចធ្វើបានដោយអញ្ជើញទៅមន្ទីរពេទ្យជាឡើងទាត់ នៅតាមមន្ទីរពេទ្យសាធារណៈធំៗ ឬជាមួយនឹងគ្រូពេទ្យឯកទេសណាមួយ ។ វាត្រូវការយ៉ាងហោចណាស់ ៦ខែនៃការប្រើថ្នាំដើម្បីព្យាបាលជម្ងឺរបេង ទោះបីជាយ៉ាងណាក្តី មានករណីយខ្លះទៀតនឹងត្រូវការប្រើពេលយូរជាងនេះ ។

ប្រសិនបើមិនបានប្រើថ្នាំពេទ្យដើម្បីព្យាបាលជម្ងឺរបេងឡើងទាត់ទេ ឬមិនបានបំពេញចប់កម្មវិធីព្យាបាលទេ នោះជម្ងឺរបេងអាចវិលត្រឡប់មកវិញ ហើយវឹតតែពិបាកព្យាបាលថែមទៀត ។

ដូច្នេះ ដើម្បីឲ្យបានជាពិជម្ងឺ នេះគឺជាការចាំបាច់ដែលត្រូវឲ្យជនដែលមានជម្ងឺរបេង ទទួលការប្រើថ្នាំព្យាបាលបានសព្វគ្រប់ ។

ប្រសិនបើមានសមាជិកណាម្នាក់នៃក្រុមគ្រួសាររបស់លោកអ្នកមានជម្ងឺរបេង នោះសមាជិកទាំងអស់នៃក្រុមគ្រួសារ និងអ្នកដែលជិតស្និទ្ធនឹងជននោះត្រូវទទួលការធ្វើតេស្តដើម្បីពិនិត្យមើលថាតើគេមានជម្ងឺរបេងឬទេ ។

ការចាក់ថ្នាំការពារជម្ងឺរបេង ***(BCG)***

ទម្រង់ការនៃការចាក់ថ្នាំការពារជម្ងឺរបេង (BCG) ឥតគ្រូវបានណែនាំឲ្យមានសំរាប់សហគមន៍អូស្ត្រាលីទូទៅឡើយ ពេលណាសភាពគ្រោះថ្នាក់នៃការកើតមានជម្ងឺរបេងគឺមានតិច ។ ទម្រង់ការនៃការចាក់ថ្នាំការពារជម្ងឺរបេងគឺគ្រាន់តែបង្ហាញច្បាប់សំរាប់ក្រុមជាក់លាក់ដែលស្ថិតនៅក្នុងសភាពគ្រោះថ្នាក់ច្រើននៃជម្ងឺរបេងប៉ុណ្ណោះ ។

តើលោកអ្នកយល់ឃើញថាលោកអ្នកមានជម្ងឺរបេងឬ?

ប្រសិនបើលោកអ្នកមានរោគសញ្ញាណាមួយដូចខាងក្រោមនេះ:

- ក្អកឥតឈប់ឈរ ។
- អស់កម្លាំងខ្លាំង ។
- បែកញើសនៅពេលយប់ ។
- ចុះទម្ងន់ ។
- ក្អកចេញឈាម ។

ចូរទៅជួបវេជ្ជបណ្ឌិតរបស់លោកអ្នកភ្លាម ។

តើមានសំណួរណាទៀតឬទេ?

ដើម្បីទទួលយកពត៌មានបន្ថែមទៀតអំពីជម្ងឺរបេង ចូរនិយាយទៅកាន់វេជ្ជបណ្ឌិតព្យាបាលជម្ងឺទូទៅរបស់លោកអ្នក (GP) ។

ជំនួយលើភាសាអាចទទួលយកបានតាមរយៈកិច្ចបំរើបកប្រែអត្ថបទ និងភាសានិយាយ (TIS) ដោយបង់ត្លៃទូរស័ព្ទដូចនៅក្នុងតំបន់ គឺលេខ 131 450 ។

ចុលលិខិតការពិតស្តីអំពីជម្ងឺរបេង គឺមានផ្តល់ជូនជាភាសាសហគមន៍ដូចតទៅនេះ :

អារ៉ាប់	ខ្មែរ	ចិន	ក្រូអេហ្ស៊ីន
ហ្គីលីពីន	ម៉ាសេដូន	ព័រទុយហ្គេ	រ៉ុស្សី
ស៊ើប្បេន	សូម៉ាលី	តាហ្គាឡុក	វៀតណាម

ដើម្បីទទួលយកពត៌មានបន្ថែមទៀត ចូរទាក់ទង:

កម្មវិធីទប់ទល់ការពារជម្ងឺរបេង
Tuberculosis Program
Disease Control Section
Human Services
GPO Box 1670N
Melbourne 3001
ទូរស័ព្ទ: (03) 9637 4115

Human Services

Peoplefirst

បោះពុម្ពផ្សាយដោយ សាខាសុខាភិបាលសាធារណៈ, ក្រសួងរដ្ឋាភិបាលវិចតូរីយ៉ា នៃកិច្ចបំរើប្រជាជន ។

រៀបចំ និងបោះពុម្ពដោយ Human Services Promotions Unit ។

(108DE96)

ខែកុម្ភៈ ឆ្នាំ១៩៩៧ 96/025